ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

**វិច្ឆិកា ២០០៦** / November 2006


**ផាន់ ដាលីស** / **Phann Dalis**

**ប៉ុន ដូរីណា** / **Pon Dorina**

**ហ៊ីង វុត្ថា** / **Hing Vutha**

**ភីម រុនស៊ីណារិទ្ធិ** / **Phim** **Runsinarith**

បកប្រែដោយ: **យូ សិទ្ធីរិទ្ធ និង យេន សុផានី**


**ភ្នំពេញ កម្ពុជា**

**Phnom Penh, Cambodia**


**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh. *Web site:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា
# Main Economic Activities of Cambodia

នៅត្រីមាសទី២ ២០០៦ វិនិយោគសាធារណៈនិងឯកជនសរុប មាន ២៤២២,១លានដុល្លារ រឺ ១៣ដង ច្រើនជាងនៅត្រីមាសដូចគ្នា ២០០៥ ។ វិនិយោគសាធារណៈ មាន ៨៥,១លានដុល្លារ រឺថយចុះ ៦.៦% រីឯ វិនិយោគឯកជន កើនឡើង ២៤ដង ធៀបនឹងពេលដូចគ្នាឆ្នាំមុន ដល់ ២៣៣៧,០ លានដុល្លារ ។ ការអនុមតិលើវិនិយោគឯកជនក្នុងវិស័យសេវាកម្ម កើនយ៉ាងខ្លាំងពី ៣០,០លានដុល្លារ នៅត្រីមាសដូចគ្នាឆ្នាំមុន ដល់ ២០៤៣,២ លានដុល្លារ រីឯ វិស័យឧស្សាហកម្ម កើន ២៤% ដល់ ២១៦,៩លានដុល្លារ ។

In the second quarter of 2006, total public and private investment was USD2422.1 m, 13 times more than the same quarter 2005. Public investment was USD85.1 m, a decrease of 6.6 percent, while private investment increased to 24 times the same period last year, to USD2337.0 m. Service sector private investment approvals increased dramatically, from USD30.0 m in the same quarter last year to USD2043.2 m, while industry showed an increase of 24 percent to USD216.9 m.

**Public and Private Investment**
**2004 Q2–2006 Q2**




*Including expansion projects.*
Source: MEF and Council for the Development of Cambodia

នៅខែសីហា ភ្ញៀវមកសំរាកលំហែនៅកម្ពុជា តំណាងឱ្យ ៩០% នៃភ្ញៀវបរទេសសរុប ។ ភ្ញៀវមកសំរាកលំហែ កើនឡើង ៧,៣% ធៀបនឹងខែមុន ដល់ ១១៦.០៣៧នាក់ រឺកើន ១៤% ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៥ ។ កូរ៉េខាងត្បូង ជាភ្ញៀវមានចំនួនច្រើនជាងគេ គឺស្មើនឹង ១៧% នៃភ្ញៀវមកសំរាកលំហែសរុប នៅខែសីហា។

In August, holiday visitor arrivals to Cambodia were 90 percent of the total foreign visitors. Holiday arrivals rose by 7.3 percent from the preceding month, to 116,037, an increase of 14 percent compared to the same month in 2005. South Korea is a major source of foreign arrivals, 17 percent of total holiday arrivals in August.

**Foreign Visitor Arrivals in Cambodia**
**June 2005–August 2006**




Source: Ministry of Tourism

នៅខែសីហា ការអនុមតិគំរោងសាងសង់នៅភ្នំពេញ ថយចុះ ១៣% ធៀបនឹងខែមុន មកត្រឹម ៣៩,២លានដុល្លារ ។ ការអនុមតិលើសំណង់ភូមិគ្រឹះនិងផ្ទះ ថយចុះ ៣១% មកត្រឹម ១,៨លានដុល្លារ និងសំណង់ផ្ទះល្វែង ចុះអស់ ១៥% មកត្រឹម ២៨.៤លានដុល្លារ រីឯ សំណង់ផ្សេងទៀត កើន ៣,៤% ដល់ ៩,០លានដុល្លារ ។ ការអនុមតិគំរោងសាងសង់ កើនបាន៥៨% ធៀបនឹងខែដូចគ្នា ឆ្នាំមុន ។

In August, construction approvals in Phnom Penh decreased by 13 percent from the previous month to USD39.2 m. Villa and house approvals declined by 31 percent to USD1.8 m, and those for flat construction by 15 percent to USD28.4 m, while other construction approvals rose by 3.4 percent to USD9.0 m. Construction approvals increased by 58 percent compared to the same month last year.

**Value of Construction Approvals:**
**Phnom Penh**
**June 2005–August 2006**




Source: Phnom Penh municipality

# ថ្លៃទំនិញ និង ស្ថានភាពពលករងាយរងគ្រោះ

# Prices and Vulnerable Workers

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញ កើនឡើង 0,៥% នៅខែកញ្ញា ធៀបនឹងខែសីហា ។ សន្ទស្សន៍ថ្លៃម្ហូបអាហារ និង ការដឹកជញ្ជូននិងទូរគមនាគមន៍ កើនឡើង 0,៩% និង 0,៧% ។ ធៀបនឹងខែកញ្ញា ២00៥ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កើនឡើង ៤,៤% ។ ថ្លៃម្ហូបអាហារ កើន ៤,៩% ហើយ ថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ កើន ៨,៦% ។

The Consumer Price Index in Phnom Penh rose in September by 0.5 percent, compared to August. The price indices of food and transportation and communication increased by 0.9 percent and 0.7 percent, respectively. Compared to September 2005, the CPI was up 4.4 percent. Food prices increased by 4.9 percent, and transportation and communications by 8.6 percent.

**Consumer Price Index**

(July–December 2000=100)




Source: National Institute of Statistics

បន្ទាប់ពីមានកំណើនអស់៧ខែជាប់ៗគ្នា ថ្លៃជាមធ្យមនៃសាំង និងម៉ាស៊ូត លើទីផ្សារនៅភ្នំពេញ ថយចុះបន្តិចមកត្រឹម ៤១0៨រៀល/លីត្រ និង ៣៣២៥រៀល/លីត្រ នៅខែតុលា ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២00៥ សាំង ឡើងថ្លៃ ៩,0% និងម៉ាស៊ូត ឡើងថ្លៃ ១៣% ។

After increasing for seven consecutive months, the average market prices of gasoline and diesel in Phnom Penh decreased slightly to 4108 riels/litre and 3325 riels/litre, respectively, in October. Compared to the same month in 2005, gasoline was up by 9.0 percent and diesel by 13 percent.

**Gasoline and Diesel Prices: Phnom Penh August 2005–October 2006**




Sources: CDRI and National Institute of Statistics

នៅខែសីហា ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ ថយចុះ ១៤% ធៀបនឹងខែឧសភា មកត្រឹម ៧៣៥0រៀល/ថ្ងៃ ហើយប្រាក់ចំណូលរបស់អ្នករត់ម៉ូតូឌុប ចុះអស់ ៦,៩% មកត្រឹម ៨១៧៥រៀល/ថ្ងៃ ។ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់គ្មានជំនាញ កើនបាន ១៤% ដល់ ៧៣0៨រៀល/ថ្ងៃ ។ ធៀបនឹងខែដូចគ្នា ឆ្នាំមុន ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ និងអ្នករត់ម៉ូតូឌុប ថយចុះ ៦,៥% និង ១៣% រីឯប្រាក់ចំណូលរបស់កម្មករសំណង់គ្មានជំនាញ កើនឡើង ២0% ។

In August, real daily earnings of cyclo drivers declined by 14 percent from May to 7350 riels/day and those of motorcycle taxi drivers by 6.9 percent to 8175 riels/day. Real daily earning of unskilled construction workers rose by 14 percent to 7308 riels/day. Compared to the same month last year, real daily earning of cyclo drivers and motorcycle taxi drivers both decreased by 6.5 and 13 percent, respectively, while those of unskilled construction workers increased by 20 percent.

**Vulnerable Workers: Phnom Penh Real Daily Average Earning Feb 04–Aug 06**




Source: CDRI

# អត្រាប្តូរប្រាក់ និង ជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស

# Exchange Rates and External Development Assistance

នៅខែតុលា ប្រាក់រៀលកម្ពុជា បន្តធ្លាក់ថ្លៃទល់នឹងដុល្លារUS ។ ធៀបនឹងខែមុន ប្រាក់រៀលធ្លាក់ថ្លៃ 0,៣% ដោយប្តូរបាន ៤១៨៨ រៀល/ដុល្លារUS ។ ប៉ុន្តែ ធៀបនឹងខែដូចគ្នាឆ្នាំមុន ប្រាក់រៀលឡើងថ្លៃ 0,៥% ទល់នឹងដុល្លារUS ។

The Cambodian riel continued to depreciate against the US dollar in October. The riel depreciated by 0.3 percent from the previous month, trading at 4188 riels/US dollar. Compared to the same month last year, the riel had appreciated by 0.5 percent against the dollar.

**Riels per US Dollar**
**August 2005–October 2006**




Sources: National Bank of Cambodia and CDRI

នៅខែតុលា អត្រាប្តូរប្រាក់រវាងប្រាក់រៀល និងប្រាក់បាតថៃ នៅថេរដោយប្តូរបានប្រហែល ១១២រៀល/បាត ។ ទល់នឹងប្រាក់ដុងវៀតណាម ប្រាក់រៀល ធ្លាក់ថ្លៃអស់ 0,៨% មកត្រឹម ២៥,២រៀល/១00ដុង ។

The exchange rate between the riel and the Thai baht remained stable at around 112 riels/baht in October. Against the Vietnamese dong, the riel depreciated by 0.8 percent to 25.2 riels per 100 dong.

**Riels against THB and VND**
**August 2005–October 2006**




Source: CDRI

ពីខែមករា ២00១ ដល់ខែធ្នូ ២00៥ គំរោងកំចីរបស់ ADB សំរាប់កម្ពុជា មានសរុប ១៦៨,២លានដុល្លារ ។ កំចីទាំងនេះ សំរាប់អនុវត្តគំរោងចំនួន ៧ គឺ ការរកចិញ្ចឹមជីវិតមានចីរភាពនៅតំបន់បឹងទន្លេសាប ការបញ្ជូនថាមពលអគ្គីសនីនៅមហាអនុតំបន់មេគង្គ វិស័យធារាសាស្រ្តនៅភាគពាយ័ព្យ ការអភិវឌ្ឍន៏ក្រុមប្រឹក្សាឃុំសង្កត់ ការកែលំអផ្លូវថ្នល់ ការគាំទ្រវិស័យសុខាភិបាល និង ការគ្រប់គ្រងបរិស្ថាននៅតំបន់បឹងទន្លេសាប ។ កំចីធំបំផុត គឺសំរាប់ការកែលំអផ្លូវថ្នល់ ដែលមានចំនួន ៥0,0លានដុល្លារ រឺ ៣0% នៃការបើកផ្តល់សរុប ។

ADB loan projects for Cambodia from January 2001 to December 2005 totalled USD168.2 m. These were for seven projects: Tonle Sap sustainable livelihoods, Greater Mekong Sub-region power transmission, north-west irrigation sector, commune council development, road improvement, health sector support and Tonle Sap environment management. The largest loan was for road improvement, USD50.0 m, 30 percent of the total loan disbursement.

**ADB Loan Projects for Cambodia**
**January 01–December 05**




Source: Asian Development Bank

# ការវិវត្តន៍រូបិយវត្ថុ

# Monetary Developments

នៅខែសីហា រូបិយវត្ថុទូទៅ M2 បានកើនឡើងក្នុងអត្រាប្រចាំឆ្នាំ ៣0% ហើយ ការផ្គត់ផ្គង់រូបិយវត្ថុ M1 កើន ៧,៣% ។ ក្នុងរយៈ១២ខែមុន រូបិយវត្ថុទូទៅ កើនឡើង ៣៣% ធៀបនឹងអត្រាកំណើន ២៩% ក្នុងរយៈមួយឆ្នាំដល់ខែកក្កដា ២00៦ ។

In August, liquidity (M2) grew at an annualised rate of 30 percent, and money supply (M1) at 7.3 percent. Over the previous 12 months, liquidity grew by 33 percent, compared to a growth rate of 29 percent in the year to July 2006.

**Monetary Survey**
**June 2005–August 2006**




Source: National Bank of Cambodia

នៅខែសីហា ឥណទានក្នុងស្រុក កើនឡើងក្នុងអត្រាប្រចាំឆ្នាំ ៤៧% រីឯ ឥណទានក្នុងវិស័យឯកជន កើនក្នុងអត្រាប្រចាំឆ្នាំ ៣៧% ។ ក្នុងរយៈ១២ខែដល់ខែសីហា ២00៦ ឥណទានក្នុងស្រុក កើនបាន ២២% ធៀបនឹងអត្រាកំណើន ១៦% ក្នុងរយៈមួយឆ្នាំដល់ខែកក្កដា ។

Domestic credit in August grew at an annualised rate of 47 percent, while private sector credit grew at an annualised rate of 37 percent. Over the 12 months to August 2006, domestic credit grew by 22 percent, compared to a growth rate of 16 percent in the year to July.

**Domestic Credit**
**February 2005–August 2006**




Source: National Bank of Cambodia

នៅខែសីហា ទ្រព្យសកម្មបរទេសសុទ្ធ និងឥណទានក្នុងវិស័យឯកជន កើនបាន ៣៩,៤ពាន់លានរៀល និង ៨៣,៤ពាន់លានរៀល ។ រីឯ ខ្ទង់ "បំណុលផ្សេងៗ" ថយចុះអស់ ២៥,៧ពាន់លានរៀល ។ បំរែបំរួលនេះត្រូវបានកាត់កងមកវិញដោយ ប្រាក់បញ្ញើរបស់រដ្ឋាភិបាល (កំណើន ១១,0 ពាន់លានរៀល) ដើម្បីបង្កើនរូបិយវត្ថុទូទៅឱ្យដល់ ១៣៧,៦ពាន់លានរៀល ។

In August, net foreign assets and private sector credit grew by KHR39.4 bn and KHR83.4 bn, respectively. 'Other items', a liability, decreased by KHR 25.7 bn. These changes were partially offset by government deposits (KHR11.0 bn increase) to give an increase in liquidity of KHR137.6 bn.

**Changes in Monetary Assets**
**August 2005–August 2006**




Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស
# External Trade

ការនាំចេញរបស់កម្ពុជានៅខែសីហា មានសរុប ២៧៩,៧លានដុល្លារ រឺកើន ៧,១% ធៀបនឹងខែមុន ។ ការនាំចេញសំលៀកបំពាក់ កើនបាន ៧,៩% ដល់ ២៧១,៧លានដុល្លារ រីឯ ការនាំចេញកៅស៊ូ ថយចុះអស់ ៩,៨% មកត្រឹម ៤,៦លានដុល្លារ ធៀបនឹងខែកក្កដា ។ ការនាំចេញត្រី គ្មានការប្រែប្រួលទេ គឺនៅត្រឹម ០,៥ លានដុល្លារ ។ ធៀបនឹងខែដូចគ្នា ឆ្នាំមុន ការនាំចេញសរុបកើនបាន ២៧% ។

Cambodian exports in August totalled USD279.7 m, 7.1 percent more than in the preceding month. Garment exports increased by 7.9 percent to USD271.7 m, while rubber exports decreased by 9.8 percent compared to July, to USD4.6 m. Fish exports remained unchanged at USD0.5 m. Compared to the same month last year, total exports rose by 27 percent.

**Cambodia: Main Exports**
**June 2005–August 2006**




Source: Customs and Excise Department

នៅខែសីហា ការនាំចូលស៊ីម៉ង់ត៍ និងដែក មានចំនួន ២៥,១ពាន់លានរៀល និង ១១,៩ពាន់លានរៀល ។ ធៀបនឹងខែមុន ការនាំចូលស៊ីម៉ង់ត៍ កើន ៧៧% រីឯ ការនាំចូលដែក ថយចុះ ២៨% ។ ការនាំចូលបារីថយចុះ ១៦% ធៀបនឹងខែកក្កដា មកត្រឹម ២១,៩ពាន់លានរៀល ។

In August, cement and steel imports were KHR25.1 bn and KHR11.9 bn, respectively. Compared to the previous month, cement imports increased by 77 percent, while steel imports declined by 28 percent. Cigarette imports decreased by 16 percent from July to KHR21.9 bn.

**Imports of Cigarettes and Construction Material**
**June 2005–August 2006**




Source: Customs and Excise Department

នៅខែសីហា ២០០៦ កម្ពុជា បាននាំចូលសាំងសរុប ១៤.៧២២តោន (១៨,៧ពាន់លានរៀល) និងម៉ាស៊ូត ៣៦.៣៦៩តោន (៣៩,៩ពាន់លានរៀល) ។ ទំហំនៃការនាំចូលម៉ាស៊ូត និងសាំង ថយចុះ ១៩% និង ០,៥% ធៀបនឹងខែមុន ។ ធៀបនឹងខែដូចគ្នា ២០០៥ ការនាំចូលសាំង និងម៉ាស៊ូត កើនបាន ៣៦% និង ៧៣% ។

Cambodia imported a total of 14,722 tonnes (KHR18.7 bn) of gasoline and 36,369 tonnes (KHR 39.9 bn) of diesel in August 2006. The volume of diesel and gasoline imports decreased by 19 percent and 0.5 percent, respectively, from the previous month. Compared to the same month in 2005, imports of gasoline and diesel increased by 36 percent and 73 percent, respectively.

**Petroleum Product Imports**
**June 2005–August 2006**




Source: Customs and Excise Department

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

ដំណើរការថវិការចរន្តរបស់រដ្ឋាភិបាល មានអតិរេក ៧៨,0ពាន់លានរៀល នៅខែមិថុនា ធៀបនឹងឱនភាព ៣១,0ពាន់លានរៀល នៅខែមុន ។ ចំណូលចរន្ត កើន ២៥% ធៀបនឹងខែមុន ដល់ ២៨៩,៤ពាន់លានរៀល ។

The government’s current budget operation surplus was KHR78.0 bn in June, compared to a deficit of KHR31.0 bn in the previous month. Current revenue increased by 25 percent from the previous month to KHR289.4 bn.

**Current Budget Operations**
**April 2005–June 2006**




*Note: Provisional for2006.*
Source: *Monthly Bulletin of Statistics* (MEF)

ចំណូលចរន្ត មាន ២៨៩,៤ពាន់លានរៀល ដោយកើនពី ២៣២,២ ពាន់លានរៀល នៅខែឧសភា ។ ចំណូលមិនមែនពន្ធ កើនទ្វេដង ធៀបនឹងខែមុនដល់ ៨៧,២ពាន់លានរៀល រីឯ ចំណូលពីពន្ធក្នុងស្រុក កើនបាន ២៥% ដល់ ៨0,៤ពាន់លានរៀល ។ ចំណូលពីការនាំចេញ និងនាំចូល ធ្លាក់ចុះអស់ ៣,៤% មកត្រឹម ១២១,៨ពាន់លានរៀល ។

Current revenue was KHR 289.4 bn, up from KHR232.2 bn in May. Non-tax revenue doubled from the previous month to KHR87.2 bn, while domestic tax revenues rose by 25 percent to KHR80.4 bn. Import and export revenues declined by 3.4 percent to KHR 121.8 bn.

**Current Budget Revenue**
**April 2005–June 2006**




*Note: Provisional for 2006.*
Source: *Monthly Bulletin of Statistics* (MEF)

នៅខែមិថុនា ចំណាយចរន្តធ្លាក់ចុះ ២0% ធៀបនឹងខែឧសភា មកត្រឹម ២១១,៥ពាន់លានរៀល ។ ចំណាយលើរដ្ឋបាលសង្គម រដ្ឋបាលសេដ្ឋកិច្ច និងសន្តិសុខនិងការពារជាតិ ធ្លាក់ចុះ ៣៧%, ១៧% និង ៥៨% ធៀបនឹងខែមុន មកត្រឹម ៧១,៤ពាន់លានរៀល, ២២,៩ពាន់លានរៀល និង ២៦,៧ពាន់លានរៀល ។ ចំណាយលើរដ្ឋបាលទូទៅ កើនឡើង ២0% ធៀបនឹងខែមុន ដល់ ៤១,៧ពាន់លានរៀល ។

In June, current expenditure decreased by 20 percent from May to KHR211.5 bn. Expenditure on social administration declined by 37 percent from the preceding month to KHR71.4 bn, on economic administration by 17 percent to KHR22.9 bn and on defence and security by 58 percent to KHR26.7 bn. General administration rose by 20 percent from the previous month to KHR41.7 bn.

**Current Budget Expenditure**
**April 2005–June 2006**




*Note: Provisional for 2006.*
Source: *Monthly Bulletin of Statistics* (MEF)

# សកម្មភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅសីហា ការនាំចេញទំនិញរបស់ US និងតំបន់អឺរ៉ូ កើនឡើង រីឯ ការនាំចេញទំនិញរបស់ជប៉ុន ធ្លាក់ចុះ ។ នៅ US និងតំបន់អឺរ៉ូ ការនាំចេញទំនិញ កើន ២.៧% និង ៤.៩% ធៀបនឹងខែមុន ដល់ ៨៧.៩៧ពាន់លានដុល្លារ និង ១៤៧.០៥ពាន់លានដុល្លារ ។ ការនាំចេញទំនិញរបស់ជប៉ុន ធ្លាក់ចុះពី ៥៤.៨១ពាន់លានដុល្លារ នៅខែកក្កដា មកត្រឹម ៥២.៩៩ពាន់លានដុល្លារ នៅសីហា ។

In August, goods exports of the US and the Euro zone increased, while goods exports of Japan decreased. US and Euro zone goods exports rose by 2.7 percent and 4.9 percent respectively from the previous month, to USD87.97 bn and USD147.05 bn, respectively. Japan's goods exports decreased from USD54.81 bn in July to USD52.99 bn in August.

### Goods Exports: US, Euro Zone and Japan




Sources: BEA, Eurostat and OECD

នៅខែសីហា ចិនមានអតិរេកពាណិជ្ជកម្ម ១៨.៨០ពាន់លានដុល្លារ ធៀបនឹង ១៤.៦២ពាន់លានដុល្លារ នៅខែកក្កដា ។ ការនាំចេញសរុប កើនបាន ១៣% ដល់ ៩០.៧៧ពាន់លានដុល្លារ រីឯ ការនាំចូលសរុប កើន ៩.៥% ដល់ ៧១.៩៧ពាន់លានដុល្លារ ។

In August, China recorded a trade surplus of USD18.80 bn, compared to USD14.62 bn in July. Total exports rose by 13 percent to USD90.77 bn, while total imports increased by 9.5 percent to USD71.97 bn.

### External Trade: China




Sources: National statistics of China

នៅខែសីហា ម៉ាឡេស៊ី មានអតិរេកពាណិជ្ជកម្ម ២.៦៧ពាន់លានដុល្លារ ធៀបនឹង ២.៣៩ពាន់លានដុល្លារ នៅខែកក្កដា ។ ការនាំចេញសរុប កើនបាន ៥.៨% ដល់ ១៤.០៨ពាន់លានដុល្លារ រីឯ ការនាំចូលសរុប កើន ៤.៥% ដល់ ១១.៤១ពាន់លានដុល្លារ ។ ផលិតផលអគ្គិសនី និង អេឡិចត្រូនិក មាន ៦.៧១ពាន់លានដុល្លារ រឺ ៤៨% នៃការនាំចេញសរុប ។

In August, Malaysia recorded a trade surplus of USD2.67 bn, compared to USD2.39 bn in July. Total exports rose by 5.8 percent to USD14.08 bn, while total imports increased by 4.5 percent to USD11.41 bn. Electrical and electronic products accounted for USD6.71 bn, 48 percent of total exports.

### External Trade: Malaysia




Source: Department of Statistics, Malaysia

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

ថ្លៃទំនិញប្រើប្រាស់នៅ US កើន ៣,៨% នៅរយៈ១ឆ្នាំដល់ខែសីហា ។ យោងតាមក្រសួងការងាររបស់ US កំណើននេះបណ្តាលមកពី ការឡើងថ្លៃថាមពល ការដឹកជញ្ជូន ថ្នាំពេទ្យ និងការស្នាក់នៅ ។ នៅកំឡុងពេលដូចគ្នា ថ្លៃទំនិញប្រើប្រាស់ កើន 0,៩% នៅជប៉ុន និង ២,៣% នៅតំបន់អឺរ៉ូ ។

US consumer prices rose by 3.8 percent in the year to August. According to the US Department of Labor, this increase stemmed from higher charges for energy, transportation, medical care and housing. During the same period, consumer prices rose by 0.9 percent in Japan and 2.3 percent in the Euro zone.

**Inflation Rate: US, Euro Zone & Japan**

(change from a year earlier)




*Note: The latest data available are for August 2006.*
Sources: IMF and *Economist* (7 October 2006)

ថ្លៃទំនិញប្រើប្រាស់ទូទៅនៅហុងកុង កើន ២,៥% នៅខែសីហា ធៀបនឹងមួយឆ្នាំមុន គឺធំជាងកំណើន ២,៣% នៅខែកក្កដា ។ រឿងនេះបណ្តាលជាសំខាន់ ពីកំណើនថ្លៃបន្លែស្រស់ ។ នៅកំឡុងពេលដូចគ្នា ថ្លៃទំនិញប្រើប្រាស់នៅចិន និងកូរ៉េខាងត្បូង កើន ១,៣% និង ២,៩% ។

Hong Kong consumer prices rose by 2.5 percent overall in August compared to a year earlier, more than the 2.3 percent increase to July. This was mainly attributable to increases in fresh vegetable prices. During the same period, consumer prices in China and South Korea increased by 1.3 percent and 2.9 percent, respectively.

**Inflation Rate: China, Hong Kong & South Korea**

(change from a year earlier)




*Note: The latest data available are for August 2006.*
Sources: IMF and *Economist* (7 October 2006)

នៅខែសីហា ២00៦ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរី កើនឡើង 0,៧% ធៀបនឹងខែដូចគ្នា ឆ្នាំមុន ។ យោងតាមនាយកដ្ឋានស្ថិតិរបស់សិង្ហបុរី រឿងនេះបណ្តាលជាសំខាន់ពីកំនើនថ្លៃម្ហូបអាហារ និងការស្នាក់នៅ។ នៅកំឡុងពេលដូចគ្នា អត្រាអតិផរណាមាន ៣,៣% នៅម៉ាឡេស៊ី និង ៣,៨% នៅថៃ ។

Singapore’s consumer price index in August was 0.7 percent higher than in the same month a year earlier. According to the Department of Statistics of Singapore, this largely reflected higher costs for food and housing. For the same period, the inflation rate was 3.3 percent in Malaysia and 3.8 percent in Thailand.

**Inflation Rate: Selected ASEAN Countries**

(change from a year earlier)




*Note: The latest data available are for August 2006.*
Sources: IMF and *Economist* (7 October 2006)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

# Exchange Rates in World Markets

នៅខែតុលា ដុល្លារUS ឡើងថ្លៃទល់នឹងរូបិវត្ថុចំបងៗផ្សេងទៀត ។ ទល់នឹងប្រាក់យ៉េនជប៉ុន វាមានប្តូរបាន ១១៨,៦យ៉េន/ដុល្លារUS រឺឡើងថ្លៃ ១,២% ធៀបនឹងខែកញ្ញា ។ ទល់នឹងអឺរ៉ូ វាប្តូរបាន 0,៧៩អឺរ៉ូ/ដុល្លារUS រឺឡើងថ្លៃ ១,0% ធៀបនឹងខែមុន ។

In October, the US dollar strengthened against other major currencies. It bought 118.6 Japanese yen, a 1.2 percent gain from September. Against the euro it traded at 0.79 EUR/USD, a 1.0 percent appreciation from the preceding month.

**EUR & JPY Against USD**

October 05–October 06 (monthly average)




Sources: Federal Reserve Bank of New York

នៅខែតុលា ប្រាក់វ៉ុនកូរ៉េខាងត្បូង ឡើងថ្លៃបន្តិចទល់នឹងដុល្លារUS ដោយប្តូរបាន ៩៥២,៤៧វ៉ុន/ដុល្លារUS ធៀបនឹង ៩៥២,៦៧វ៉ុន/ដុល្លារUS នៅខែមុន ។ នៅកំឡុងពេលដូចគ្នា ដុល្លារហុងកុង ធ្លាក់ថ្លៃបន្តិចទល់នឹងដុល្លារUS ដោយប្តូរបាន ៧,៧៨ដុល្លារហុងកុង/ដុល្លារUS ។

In October, the South Korean won slightly appreciated against the US dollar, trading at 952.47 KRW/USD compared with 952.67 KRW/USD a month earlier. During the same period, the Hong Kong dollar marginally depreciated against its US counterpart, trading at 7.78 HKD/USD.

**KRW & HKD Against USD**

October 05–October 06 (monthly average)




Sources: Federal Reserve Bank of New York

នៅខែតុលា ដុល្លារសិង្ហបុរី ឡើងថ្លៃបន្តិចទល់នឹងដុល្លារUS ដោយប្តូរបាន ១,៥៧៨ដុល្លារសិង្ហបុរី/ដុល្លារUS ធៀបនឹង ១,៥៨0ដុល្លារសិង្ហបុរី/ដុល្លារUS នៅខែមុន ។ ប្រាក់បាតថៃ ក៏ឡើងថ្លៃទល់នឹងដុល្លារUS ដែរ ដោយប្តូរបាន ៣៧,២៩បាត/ដុល្លារUS (៣៧,៤៣បាត/ដុល្លារUS នៅខែកញ្ញា) ។

The Singapore dollar in October gained slightly against the US dollar, trading at 1.578 SGD/USD compared with 1.580 SGD/USD in the previous month. The Thai baht also strengthened against the US dollar, exchanging at 37.29 THB/USD (37.43 THB/USD in September).

**THB & SGD Against USD**

October 05-October 06 (Monthly average)




Sources: Federal Reserve Bank of New York

# សកម្មភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នៅខែកញ្ញា ថ្លៃអង្ករពិភពលោក កើនឡើង លើកលែងតែនៅប្រទេសថៃ ដែលថ្លៃអង្ករ Thai 100%B ធ្លាក់ចុះមកត្រឹម ២៨៧.៥២ដុល្លារ/តោន ធៀបនឹង ២៨៩.៣៣ដុល្លារ/តោន នៅខែសីហា ។ សន្ទស្សន៍ថ្លៃអន្តរជាតិ កើនឡើងដល់ ១៣២.២ពិន្ទុ ធៀបនឹង ១៣០.០ពិន្ទុ នៅខែសីហា ។ នៅ US ថ្លៃនាំចេញរបស់អង្ករ ឡើងដល់ ៣៧៦.៤១ដុល្លារ/តោន ធៀបនឹង ៣៥១.០១ដុល្លារ/តោន នៅខែសីហា ។

In September, world rice prices increased, except in Thailand, where the price of Thai 100% B fell to USD287.52 per tonne from USD289.33 in August. The international price index (IPO) rose to 132.2, against 130.0 in August. In the United States, the export price increased to USD376.41 per tonne, against USD351.01 in August.

**International Prices Index and Export Rice Prices**
(USD/tonne FOB)




Sources: Osiriz/InfoArroz and InterRice.

ថ្លៃសណ្តែកសៀង និងពោត កើនឡើងនៅខែតុលា រីឯថ្លៃប្រេងឆា នៅខែកញ្ញា មិនទាន់មានផ្សព្វផ្សាយនៅឡើយទេ ។ សណ្តែកសៀង លក់ថ្លៃ ២១៥.០១ដុល្លារ/តោន ដោយឡើងថ្លៃពី ២០២.៣៤ដុល្លារ/តោន នៅខែកញ្ញា ។ ពោតលក់ថ្លៃ ១២៧.៦៥ដុល្លារ/តោន ដោយឡើងថ្លៃពី ១០៨.២១ដុលារ/តោន នៅខែកញ្ញា ។

The prices of soybeans and maize increased in October, while the September price of palm oil has not yet been released. Soybeans sold at USD215.01 per tonne, up from USD202.34 in September. Maize was USD127.65 per tonne, up from USD108.21 in September.

**International Prices of Soybeans, Maize and Palm Oil**
(USD/tonne FOB)




Source: Food and Agriculture Organisation (FAO)

នៅខែតុលា ថ្លៃប្រេងឆៅ សាំង និងម៉ាស៊ូត ធ្លាក់ចុះ ។ ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ OPEC គឺ ៥៥.៤៧ដុល្លារ/ធុង ធៀបនឹង ៦១.៦៤ដុល្លារ/ធុង នៅខែកញ្ញា ។ នៅ US Gulf Coast ថ្លៃប្រេងសាំងធម្មតា (អុកតាន ៨៧) ធ្លាក់ចុះ ៦.៣% មកត្រឹម ៣៩.៨៦សេន/លីត្រ ធៀបនឹង ៤២.៥៦សេន/លីត្រ នៅខែកញ្ញា ។ ថ្លៃម៉ាស៊ូត (មានលាយស្ពាន់ធ័រតិច លេខ២) ក៏ធ្លាក់ចុះ ៧.៣% ធៀបនឹងខែមុន ដល់ ៤៥.១៤សេន/លីត្រ ។

In October, the prices of crude oil, gasoline and diesel decreased. The OPEC spot price of crude oil was USD55.47 per barrel, against USD61.64 in September. Regular gasoline (87 octane) prices on the US Gulf Coast decreased by 6.3 percent to 39.86 cents per litre compared to 42.56 cents per litre in September. The diesel price (low sulphur No.2) on the US Gulf Coast also declined considerably by 7.3 percent from the previous month to 45.14 cents per litre.

**Prices of Crude Oil, Gasoline and Diesel**




Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច
# Economic News

***នាំយកអគ្គិសនីតំលៃថោក និងគួរឱ្យទុកចិត្ត ទៅដល់ក្រុងព្រះសីហនុ:*** ធនាគារអភិវឌ្ឍន៏អាស៊ី (ADB) នឹងជួយផ្តល់ថាមពលគួរឱ្យទុកចិត្ត និងមានតំលៃថោកជាងមុន ដល់ក្រុងព្រះសីហនុ និងតំបន់ជិតខាង ខាងនៅភាគខាងត្បូងកម្ពុជា តាមរយៈកំចី ២០លានដុល្លារ ។ ADB រួមជាមួយដៃគូអភិវឌ្ឍន៏ដទៃទៀត កំពុងជួយរដ្ឋាភិបាលក្នុងការកសាងខ្សែបញ្ជូនចរន្តអគ្គិសនីទំហំធំកំលាំង ២៣០គីឡូវ៉ុល នៅភាគខាងត្បូងនៃប្រទេស ដែលនឹងអនុញ្ញាតឱ្យនាំចូលនូវអគ្គិសនីតំលៃថោកពីវៀតណាម ដើម្បីបំពេញតំរូវការថាមពលដែលកំពុងកើនឡើងយ៉ាងលឿន ។ គំរោងថ្មីនេះ នឹងបន្លាយខ្សែបញ្ជូនចរន្តអគ្គិសនី ២៣០គីឡូវ៉ុល ពីខេត្តកំពតដើម្បីផ្គត់ផ្គង់ថាមពលដល់ក្រុងព្រះសីហនុ រួមទាំងតំបន់ជនបទនៅតាមបណ្តោយខ្សែបញ្ជូនចរន្តនេះផងដែរ ។ ម្យ៉ាងទៀត នឹងមានការកសាងស្ថានីយរង និងកន្លែងចែកចាយលក់ដុំផងដែរ ។ គំរោងនឹងជួយសំរួលឱ្យមានការចុះថ្លៃចរន្តអគ្គិសនីនៅក្រុងព្រះសីហនុ ។ លើសពីនេះ វាផ្តល់លទ្ធភាពឱ្យគ្រួសារនៅជនបទដែលរស់នៅតាមបណ្តោយខ្សែបញ្ជូនចរន្ត អាចទទួលបានអគ្គិសនីគួរឱ្យទុកចិត្ត និងមានតំលៃថោក ពីបណ្តាញចែកចាយជាលើកដំបូង ។ គំរោងនេះរំពឹងថានឹងបញ្ចប់នៅចុងឆ្នាំ ២០១០ និងចំណាយអស់ប្រមាណ ៥២,៣៦លានដុល្លារ ។ ធនាគារជប៉ុនសំរាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ នឹងផ្តល់កំចី ២២,៣លានដុល្លារ ដើម្បីជួយបំពេញការចំណាយរបស់គំរោង ហើយរដ្ឋាភិបាលកម្ពុជា នឹងបន្ថែមបង្គ្រប់ ។

***Bringing cheap and reliable electricity to Sihanoukville:*** The ADB will help provide reliable and cheaper power to the municipality of Sihanoukville and its adjacent areas in southern Cambodia through a US$20 million loan. The ADB, together with other development partners, is helping the government build the 230 kilovolt backbone transmission line in the southern part of the country, which will allow the import of cheaper electricity from Vietnam to meet rapidly increasing power demand. This new project will extend the 230 kV transmission line from Kampot to supply power to Sihanoukville, including to rural areas along the transmission corridor. It will also build associated substations and bulk supply distribution facilities. The project will facilitate reduction in electricity prices in Sihanoukville. In addition, it will allow rural households living along the transmission corridor to have access to reliable and lower cost electricity from the grid for the first time. The project is expected to be completed at the end of 2010 and will cost an estimated $52.36 million. The Japan Bank for International Cooperation will provide a $22.3 million loan to meet a portion of the project cost, and the Cambodian government will shoulder the balance. *(Cited from http://adb.org/News 23 October 2006*

***ផលិតផលកម្ពុជា ទទួលបានអត្រាពន្ធនាំចូលស្មើសូន្យ:*** ក្រសួងពាណិជ្ជកម្មវៀតណាម បានប្រកាសអត្រាពន្ធនាំចូលស្មើសូន្យសំរាប់ផលិតផលកសិកម្មកម្ពុជា ដែលនាំចូលទៅវៀតណាម ។ អត្រាពន្ធនាំចូលស្មើសូន្យ នឹងផ្តល់ដល់ដំណាំកសិកម្មកម្ពុជាចំនួន ៤០ប្រភេទ រួមមាន ដំឡូងមី ដំឡូងជ្វា គ្រាប់ស្វាយចន្ទី ម្រេច អង្ករ ពោត សណ្តែកសៀង សណ្តែកដី គ្រាប់ល្ហុងខ្វែង ល្ង សារ៉ាយសមុទ្រ អំពៅ និងជ័រកៅស៊ូ ។ ផលិតផលទាំងនេះ នឹងត្រូវប្រមូល បន្ទាប់ពីមានការកែច្នៃពេញលេញនៅកម្ពុជាប៉ុណ្ណោះ ។ ផលិតផលត្រូវមានលិខិតបញ្ជាក់ពីប្រភពដើម ចេញដោយក្រសួងពាណិជ្ជកម្មកម្ពុជា និងត្រូវដឹកជញ្ជូនដោយផ្ទាល់ពីកម្ពុជាទៅវៀតណាម ។

***Cambodian products to enjoy zero import tax rates:*** The Vietnamese Ministry of Trade has declared an import tax rate of zero percent to be applied to Cambodian agricultural products imported into Vietnam. The zero import tax rate will be applicable to 40 Cambodian agricultural categories, including cassava, sweet potato, cashew nuts, pepper, rice, corn, soybeans, peanut, castor beans, sesame, seaweed, sugar cane and raw rubber. These products have to be collected manufactured or fully processed in Cambodia. The products will have to be granted a certificate of origin by the Cambodian Ministry of Trade and be transported directly from Cambodia to Vietnam. *(Cited from english.vietnamnet.vn 14 October 2006)*